**ជំពូកទី ៩**

# បម្រែបម្រួលថាមពល និងប្រតិកម្មទៅមក

យើងរស់នៅ និងធ្វើចលនានៅក្នុងបរិយាកាសដែលមានអាសូតប្រមាណ ៤/៥ នៃខ្យល់។ អាសូតជាឧស្ម័ននិចលអសកម្មដែលជាប្រការល្អមួយសម្រាប់ជីវិតរបស់យើង។ យើងអាចដកដង្ហើមស្រូបឧស្ម័ននេះចូលហើយបញ្ចេញមកវិញដោយ គ្មានការប្រែប្រួលអ្វីឡើយ។ ខ្លួនមនុស្សយើងមិនអាចប្រើឧស្ម័ននេះដោយផ្ទាល់ទេ ប៉ុន្តែចំពោះវិធីមិនផ្ទាល់វិញជាបញ្ហាមួយផ្សេងទៀត។ យើងមិនអាចរស់នៅដោយគ្មានវាបានទេ ពីព្រោះគ្រាប់ធញ្ញជាតិត្រូវការអាសូត ហើយមនុស្សយើងក៏ត្រូវការគ្រាប់ធញ្ញជាតិដែរ។ ដូចនេះនៅទូទាំងពិភពលោក យើងប្រើថាមពលជាច្រើនសម្រាប់ទាញយកអាសូតចេញពីបរិយាកាស និងធ្វើជាជីដើម្បីឱ្យដីមានជីជាតិ។

យើងអាចទាញយកអាសូតដោយបំលែងវាឱ្យទៅជាអាម៉ូញាក់។ ការបំលែងនេះមានការលំបាកណាស់ព្រោះអាសូតជាធាតុមិនសកម្ម។ មិនតែប៉ុណ្ណោះក៏មានឧបសគ្គមួយទៀតដែរ គឺប្រតិកម្មរវាងអាសូត និងអ៊ីដ្រូសែនគឺជាប្រតិកម្មទៅមក ដូចជាប្រតិកម្មឧស្សាហកម្មសំខាន់ៗមួយចំនួនទៀតដែរ។ ប្រតិកម្មនេះអាចទៅមុខ ហើយក៏អាចត្រឡប់ថយក្រោយវិញ ដែរ។ តាមពិតយើងមិនអាចប្តូរបរិមាណអាសូត និងអ៊ីដ្រូសែនឱ្យទៅជាអាម៉ូញាក់ទាំងអស់បាននោះទេ។

## ១ ប្រតិកម្មបញ្ចេញ និងស្រូបកម្ដៅ

ប្រតិកម្មគីមីស្ទើរតែទាំងអស់មានបម្រែបម្រួលថាមពល។ ថាមពលត្រូវបានបញ្ចេញ ឬស្រូបក្នុងទម្រង់ជាកម្ដៅ។ ដូចនេះយើងចែកប្រតិកម្មជាពីរក្រុមគឺ **ប្រតិកម្មបញ្ចេញកម្ដៅ និងប្រតិកម្មស្រូបកម្ដៅ។**

### ១.១ ប្រតិកម្មបញ្ចេញកម្ដៅ



យើងអាចដឹងយ៉ាងងាយថាមានថាមពលបញ្ចេញ នៅពេលដែកមានប្រតិកម្មជាមួយស្ពាន់ធ័រ។ វានៅតែឆេះរង្គើទោះបីជាយើងបិទចំពុះប៊ុនសិនក៏ដោយ។



ការលាយប្រាក់នីត្រាត និងសូដ្យូមក្លរួ គេនឹងទទួលបានកករពណ៌ស ហើយសីតុណ្ហភាពរបស់ល្បាយនឹងកើនឡើង។



នៅពេលយើងថែមទឹកទៅលើកាល់ស្យូមអុកស៊ីត វានឹងបញ្ចេញកម្ដៅហើយសីតុណ្ហភាពនឹងកើន។

ប្រតិកម្មទាំងបីទាំងខាងលើនេះវាបញ្ចេញថាមពលកម្ដៅ ជាប្រតិកម្មបញ្ចេញកម្ដៅ។ យើងអាចសង្ខេបប្រតិកម្មខាងលើនេះដូចខាងក្រោម ÷

អង្គធាតុប្រតិករ ⟶ ផលិតផល + ថាមពលកម្ដៅ

ថាមពលកម្ដៅនេះត្រូវផ្ទេរទៅឱ្យមជ្ឈដ្ឋាននៅជុំវិញវា។

**បញ្ចេញកម្ដៅ :** ថាមពលត្រូវផ្ទេរទៅមជ្ឈដ្ឋានជុំវិញ



### ១.១.១ ដ្យាក្រាមកម្រិតថាមពល

ប្រសិនបើប្រតិកម្មទាំងមូលបញ្ចេញថាមពល មានន័យថាផលិតផលមានថាមពលតិចជាងអង្គធាតុប្រតិករ។ យើងអាចបង្ហាញបាតុភូតនេះដោយប្រើដ្យាក្រាមកម្រិតថាមពលដូចរូបខាងស្ដាំនេះ។




### ១.១.២ ឧទាហរណ៍ផ្សេងៗទៀតនៃប្រតិកម្មបញ្ចេញកម្ដៅ

- ការបន្សាបអាស៊ីតដោយអាល់កាលី។
- ចំហេះឥន្ធនៈ។ ប្រសិនបើវាមិនបញ្ចេញកម្ដៅ នោះវាមិនមែនជាឥន្ធនៈល្អទេ។
- ដំណកដង្ហើមនៅក្នុងសារពាង្គកាយ។ វាផ្ដល់នូវថាមពលដើម្បីធ្វើឱ្យបេះដូង និងសួតរបស់យើងដំណើរការ ហើយនិងរក្សាកម្ដៅ និងចលនា។

**ស៊ូល**

ខ្នាតរបស់ថាមពលគឺ ស៊ូល (J)

(ដូចក្នុងរូបវិទ្យាដែរ)

## ១.២ ប្រតិកម្មស្រូបកម្ដៅ



នៅពេលដែលបារ្យូមអ៊ីដ្រុកស៊ីតមានប្រតិកម្មជាមួយអាម៉ូញ៉ូមក្លរួ សីតុណ្ហភាពថយចុះ។



ប្រតិកម្មបន្សាបរវាងអាស៊ីតអេតាណូអ៊ិចដោយសូដ្យូមកាបូណាតក៏ធ្វើឱ្យសីតុណ្ហភាពថយចុះដែរ។



ស៊ីប៊ីត(Sherbet)គឺជាល្បាយអាស៊ីតស៊ីទ្រិច និងសូដ្យូមអ៊ីដ្រូសែនកាបូណាត។ ប្រតិកម្មបន្សាយធ្វើឱ្យត្រជាក់អណ្ដាត។

ពេលនេះប្រតិកម្មស្រូបយកថាមពលកម្ដៅ ។ វាជាប្រតិកម្មស្រូបកម្ដៅ យើងអាចសង្ខេបប្រតិកម្មដូចខាងក្រោម ÷

អង្គធាតុប្រតិករ + *ថាមពលកម្ដៅ* ⟶ ផលិតផល

ថាមពលកម្ដៅត្រូវផ្ទេរមកពីមជ្ឈដ្ឋានជុំវិញ ។

### ១.២.១ ដ្យាក្រាមកម្រិតថាមពល

ប្រសិនបើប្រតិកម្មទាំងមូលស្រូបកម្ដៅមានន័យថាផលិតផលមានថាមពលច្រើនជាងអង្គធាតុប្រតិករ ។ យើងអាចបង្ហាញតាមរយៈដ្យាក្រាមកម្រិតថាមពលដូចរូបខាងស្ដាំនេះ ។ អង្គធាតុប្រតិករត្រូវទទួលថាមពលរហូតដល់ផុតចន្លោះថាមពលនេះដើម្បីឱ្យប្រតិកម្មកើតមានឡើង ដូចនេះវាត្រូវស្រូបថាមពលពីមជ្ឈដ្ឋានជុំវិញ ។







### ១.២.២ ឧទាហរណ៍ផ្សេងៗនៃប្រតិកម្មស្រូបកម្ដៅ

ប្រតិកម្មទាំងអស់ខាងលើកើតឡើងភ្លាមៗបន្ទាប់ពីលាយសមាសធាតុទាំងនោះចូលគ្នា ប៉ុន្តែនៅក្នុងប្រតិកម្មស្រូបកម្ដៅដទៃទៀត យើងត្រូវតែផ្តល់ថាមពលដើម្បីឱ្យប្រតិកម្មចាប់ផ្តើមកើតឡើង និងបន្តដំណើរការ ។

*ឧទាហរណ៍* - ប្រតិកម្មដែលកើតឡើងក្នុងម្ហូបអាហារពេលយើងចម្អិនវា ។

- ប្រតិកម្មប៉ូលីមែកម្មនៃអេតែន ឱ្យជាប៉ូលីអេតែន ។
- ប្រតិកម្មរស្មីសំយោគ ដែលក្នុងប្រតិកម្មនេះវាទទួលយកថាមពលពីពន្លឺព្រះអាទិត្យ ។
- ប្រតិកម្មក្នុងអគ្គិសនីវិភាគ ។ ថាមពលត្រូវផ្តល់ក្នុងទម្រង់ជាអគ្គិសនី ។

**សំណួរ**

1. ដូចម្ដេចដែលហៅថា ÷

   ក- ប្រតិកម្មស្រូបកម្ដៅ?

   ខ- ប្រតិកម្មបញ្ចេញកម្ដៅ?

2. តើប្រតិកម្មនីមួយៗខាងក្រោមនេះជាប្រតិកម្មស្រូប ឬបញ្ចេញកម្ដៅ?

   ក- ចំហេះទៀន

   ខ- ប្រតិកម្មរវាងសូដ្យូម និងទឹក

   គ- បម្រែបម្រួលពីស៊ុតឆៅទៅជាស៊ុតឆ្អិន

3. តើខ្នាតរបស់ថាមពលគិតជាអ្វី?

4. តើប្រភេទប្រតិកម្មអ្វីដែលក្នុងនោះថាមពលកម្ដៅត្រូវបានផ្ទេរពីសារធាតុគីមីទៅមជ្ឈដ្ឋានជុំវិញ?

5. ចូរគូសគំនូសតាងកម្រិតថាមពលសម្រាប់ ÷

ក- ប្រតិកម្មស្រូបកម្ដៅ

ខ- ប្រតិកម្មបញ្ចេញកម្ដៅ

# ២ ការពន្យល់ពីបម្រែបម្រួលថាមពល

## ២.១ ការផ្ដាច់ និងការបង្កើតសម្ព័ន្ធ

ល្បាយអ៊ីដ្រូសែន និង ក្លរផ្ទុះនៅពេលមានពន្លឺព្រះអាទិត្យ ។

អ៊ីដ្រូសែន + ក្លរ ⟶ អ៊ីដ្រូសែនក្លរួ

ការផ្ទុះដែលកើតឡើងនេះបង្ហាញឱ្យឃើញថា ថាមពលត្រូវបានបញ្ចេញ ។ តើថាមពលដែលបញ្ចេញនេះបានមកពីណា ? ចូរពិនិត្យមើលថាតើមានអ្វីកើតឡើង ។




1 គេលាយម៉ូលេគុលក្លរ និងអ៊ីដ្រូសែនបញ្ចូលគ្នា ។ អាតូមទាំងឡាយនៅក្នុងម៉ូលេគុលនីមួយៗ ចងសម្ព័ន្ធនឹងគ្នាដោយសម្ព័ន្ធកូវ៉ាឡង់ ។

2 សម្ព័ន្ធទាំងនេះត្រូវផ្ដាច់មុនពេលប្រតិកម្មកើតមានឡើង ។ ក្នុងដំណាក់កាលនេះ វាស្រូបថាមពល វាជាលំនាំស្រូបកម្ដៅ ។

3 ពេលនេះសម្ព័ន្ធថ្មីបានកកើតរវាងអាតូមក្លរ និងអាតូមអ៊ីដ្រូសែន ។ ដំណាក់កាលនេះវាផ្ដល់ថាមពលវាជាប្រតិកម្មបញ្ចេញកម្ដៅ ។

ថាមពលដែលបានបញ្ចេញនៅដំណាក់កាលទី៣ ធំជាងថាមពលដែលស្រូបយកនៅដំណាក់កាលទី២ ។ ហេតុនេះហើយ បានជាប្រតិកម្មទាំងមូលគឺជាប្រតិកម្មបញ្ចេញកម្ដៅ ។ *ប្រសិនបើថាមពលដែលបញ្ចេញនៅក្នុងការបង្កើតសម្ព័ន្ធធំជាងថាមពលដែលត្រូវការនៅក្នុងការផ្ដាច់សម្ព័ន្ធ នោះប្រតិកម្មជាប្រតិកម្មបញ្ចេញកម្ដៅ ។*

ចូរពិនិត្យមើលថាតើមានអ្វីកើតឡើង ប្រសិនបើយើងដុតកម្ដៅអាម៉ូញាក់ឱ្យខ្លាំង ។ ពេលនេះយើងបង្ហាញម៉ូលេគុលតាមវិធីសាមញ្ញដែលយើងប្រើរដ្ឋសញ្ញា( -) សម្រាប់តាងឱ្យសម្ព័ន្ធនីមួយៗ( គ្រប់អាតូមអាសូតទាំងអស់មានរដ្ឋសញ្ញាបីព្រោះវាមានសម្ព័ន្ធបី) ។



1 ម៉ូលេគុលរបស់វាចងសម្ព័ន្ធកូវ៉ាឡង់រវាងអាតូមអ៊ីដ្រូសែន និងអាសូត ។

2 ដើម្បីឱ្យប្រតិកម្មកើតមានឡើងសម្ព័ន្ធទាំងនេះត្រូវផ្តាច់ចេញពីគ្នា ។ ដំណាក់កាលនេះស្រូបថាមពល ដែលបានមកពីការដុតកម្តៅ ។ វាជាលំនាំស្រូបកម្តៅ ។

3 ពេលនេះអាតូមអ៊ីដ្រូសែនចងសម្ព័ន្ធជាមួយគ្នា ដូចគ្នានឹងអាតូមអាសូតដែរ ។ ដំណាក់កាលនេះវាបញ្ចេញថាមពល ។ វាជាប្រតិកម្មបញ្ចេញកម្តៅ ។

ប៉ុន្តែពេលនេះថាមពលដែលបញ្ចេញនៅដំណាក់កាលទី៣ តូចជាងថាមពលដែលត្រូវផ្តល់ឱ្យនៅដំណាក់កាលទី២ ។ ដូចនេះប្រតិកម្មទាំងមូលជាប្រតិកម្មស្រូបកម្តៅ ។ *ប្រសិនបើថាមពលដែលបញ្ចេញនៅក្នុងការចងសម្ព័ន្ធ តូចជាងថាមពលដែលត្រូវការដើម្បីផ្តាច់សម្ព័ន្ធ ប្រតិកម្មនោះជាប្រតិកម្មស្រូបកម្តៅ ។*

## ២.២ ថាមពលសម្ព័ន្ធ

គីមីវិទូទាំងឡាយបានរកឃើញបរិមាណថាមពលដែលត្រូវការដើម្បីផ្តាច់សម្ព័ន្ធនៅក្នុងម៉ូលេគុល ។ គេហៅថាមពលនេះថា ***ថាមពលសម្ព័ន្ធ ។*** ថាមពលនេះគិតជាគីឡូស៊ូល (kJ) ។ ខាងស្តាំនេះជាថាមពលសម្ព័ន្ធមួយចំនួន ។ ដើម្បីផ្តាច់សម្ព័ន្ធក្លរនៅក្នុងម៉ូលេគុលក្លរឱ្យទៅជាអាតូមក្លរ វាត្រូវការថាមពល 242 kJ ។ ប៉ុន្តែនៅពេលអាតូមរបស់វាចងសម្ព័ន្ធបង្កើតបានជាម៉ូលេគុលឡើងវិញ វាបញ្ចេញថាមពល 242 kJ ដែរ ។ *ថាមពលសម្ព័ន្ធ ជាថាមពលដែលត្រូវការដើម្បីផ្តាច់សម្ព័ន្ធ ឬបញ្ចេញនៅពេលបង្កើតសម្ព័ន្ធ ។*

| **ថាមពលសម្ព័ន្ធ** kJ | |
|---|---|
| H-H | 436 |
| Cl-Cl | 242 |
| C-C | 346 |
| C=C | 612 |
| C-O | 358 |
| O=O | 498 |
| O-H | 464 |
| N≡N | 946 |
| N-H | 391 |

**គេរកវាឃើញតាមរយៈម៉ាសម៉ូលរបស់សមាសធាតុជាក្រាម ។**

## ២.៣ ការគណនាបម្រែបម្រួលថាមពលនៅក្នុងប្រតិកម្ម

***ប្រតិកម្មរវាងក្លរ និង អ៊ីដ្រូសែន***

H—H + Cl—Cl ⟶ 2 H—Cl

*ថាមពលស្រូបដើម្បីផ្តាច់សម្ព័ន្ធ*

1 × H—H 436 kJ
1 × Cl—Cl <u>242 kJ</u>

ថាមពលស្រូបសរុប 678 kJ

*ថាមពលបញ្ចេញពីការបង្កើតសម្ព័ន្ធ*

2 × H—Cl 2 ×431 kJ = 862 kJ

ថាមពលបញ្ចេញ — ថាមពលស្រូប 862 kJ − <u>678 kJ</u> = **184 kJ**



សរុបមកប្រតិកម្មទាំងមូលបញ្ចេញថាមពល **184 kJ** ។

***ប្រតិកម្មបំបែកអាម៉ូញ៉ាក់***

$2\,NH_3 \longrightarrow N{\equiv}N + 3\,H{-}H$




*ថាមពលស្រូបដើម្បីផ្តាច់សម្ព័ន្ធ*

| | |
|---|---|
| 6 × N—H | 6 × 391 kJ = 2346 kJ |

*ថាមពលបញ្ចេញពីការបង្កើតសម្ព័ន្ធ*

| | |
|---|---|
| 1 × N≡N | 946 kJ |
| 3 × H—H | 3×436=1308 kJ |
| ថាមពលបញ្ចេញសរុប | **2254 kJ** |
| ថាមពលស្រូប — ថាមពលបញ្ចេញ | 2346 kJ − 2254 kJ |
| | **92 kJ** |

សរុបមកប្រតិកម្មទាំងមូលស្រូបថាមពល 92 **kJ** ។

សំគាល់ ទោះបីជាប្រតិកម្មគីមីណាមួយមានបន្ទុះខ្លាំងក៏ដោយ ក៏វាត្រូវស្រូបថាមពលដើម្បីផ្តាច់សម្ព័ន្ធ និងផ្តើមឱ្យប្រតិកម្មកើតឡើងដែរ។ ថាមពលនេះគេឱ្យឈ្មោះថា ***ថាមពលសកម្មកម្ម។*** ថាមពលនេះអាចបានមកពីការដុតឈើគូស ឬចំពុះប៊ុនស៊ិន ឬពន្លឺព្រះអាទិត្យ ។

## ២.៤ ចំហេះឥន្ធនៈ

ឥន្ធនៈរងអុកស៊ីតកម្មនៅពេលដែលវាឆេះ ហើយប្រតិកម្មនេះជាលំនាំបញ្ចេញកម្តៅ ។

| ឥន្ធនៈ | ប្រើសម្រាប់ | សមីការចំហេះក្នុងអុកស៊ីសែន | ថាមពល (kJ) ដែលបញ្ចេញដោយការដុតក្នុង១ម៉ូលឥន្ធនៈជាក្រាម |
|---|---|---|---|
| មេតាន | ដុតកម្តៅ ដាំស្ល | $CH_4(g) + 2\,O_2(g) \longrightarrow CO_2(g) + 2\,H_2O(g)$ | 890 |
| អ៊ីដ្រូសែន | ឥន្ធនៈរបស់រ៉ុកកែត | $2H_2(g) + O_2(g) \longrightarrow 2\,H_2O(g)$ | 486 |
| គ្លុយកូស | ឥន្ធនៈក្នុងខ្លួនមនុស្ស | $C_6H_{12}O_6(aq) + 6\,O_2(g) \rightarrow 6\,CO_2(g) + 6\,H_2O(g)$ | 2803 |

### សំណួរ

1. នៅពេលក្លរ និងអ៊ីដ្រូសែន មានប្រតិកម្មជាមួយគ្នា ÷

   ក- តើផ្នែកណានៃប្រតិកម្មជាលំនាំស្រូបកម្តៅ?

   ខ- តើផ្នែកណានៃប្រតិកម្មជាលំនាំបញ្ចេញកម្តៅ?

   គ- ហេតុអ្វីបានជាប្រតិកម្មទាំងមូលបញ្ចេញថាមពល?

2. ក- ចូរសរសេរសមីការតាងប្រតិកម្មរវាងអ៊ីដ្រូសែន និងអុកស៊ីសែនដោយបញ្ជាក់ពីរជួសញ្ញា( - ) តាងសម្ព័ន្ធ។ តើមានសម្ព័ន្ធពីរជាន់ឬទេ ?

ខ- ចូរគណនាបម្រែបម្រួលថាមពលសម្រាប់ប្រតិកម្មនេះ?

3. តើចំហេះឥន្ធនៈមួយណាដែលមិនប៉ះពាល់ដល់បរិស្ថាន?

ក- ចំហេះមេតាន

ខ- ចំហេះអ៊ីដ្រូសែន

គ- ចំហេះគ្លុយកូស

៤. ចូរគូរគំនូសតាងថាមពលសម្រាប់ប្រតិកម្មចំហេះមេតាន ឧស្ម័នសម្រាប់ចម្អិនអាហារ។ តើយើងអាចផ្តល់ថាមពលសកម្មកម្មដូចម្តេច?

# ៣ ប្រតិកម្មទៅមក

## ៣.១ ការដុតកម្តៅក្រាមទង់ដែង II ស៊ុលផាត...



នៅពេលដែលយើងដុតកម្តៅក្រាម ទង់ដែង II ស៊ុលផាតពណ៌ខៀវ នោះវានឹងក្លាយជា ទង់ដែង II ស៊ុលផាតអានីត ដែលជាម្សៅពណ៌ស។

$CuSO_4.5H_2O\ (s) \rightarrow CuSO_4(s) + 5\ H_2O\ (g)$



ប្រតិកម្មនេះងាយត្រលប់មកវិញ ដោយគ្រាន់តែបន្ថែមទឹកចូល។ ម្សៅពណ៌សនឹងប្រែជាពណ៌ខៀវឡើងវិញ។ គេប្រើវិធីនេះដើម្បីធ្វើតេស្តពីវត្តមានទឹក។

$CuSO_4\ (s) + 5H_2O\ (l) \rightarrow CuSO_4.\ 5\ H_2O\ (s)$

*សំគាល់*

### ក្រាមអ៊ីដ្រាតេ

- ក្រាមទង់ដែង II ស៊ុលផាតពណ៌ខៀវដែលមានទឹក ហៅថា **ក្រាមអ៊ីដ្រាតេ**។
- សមាសធាតុពណ៌ខៀវមានជាតិទឹក។
- សមាសធាតុដែលមានពណ៌ស ជាសមាសធាតុអានីត (គ្មានជាតិទឹក)។

### ការធ្វើតេស្តពីវត្តមានទឹក

- វាអាចប្តូរពណ៌ទង់ដែង II ស៊ុលផាតអានីត ពណ៌សទៅជាពណ៌ខៀវ
- វាប្តូរពណ៌ក្រដាសកូបាល់ក្លរួដែលមានពណ៌ខៀវទៅជាពណ៌ផ្កាឈូក។ បម្រែបម្រួលទាំងនេះសុទ្ធតែមានទិសដៅទៅមក។

ប្រតិកម្មខាងលើនេះជាប្រតិកម្មទៅមក វាអាចមានទិសដៅពីរ ។ ប្រតិកម្មទី 1 ជាប្រតិកម្មទៅ ហើយប្រតិកម្មទី 2 ជាប្រតិកម្មច្រាស ។ យើងប្រើសញ្ញា ( $\underset{2}{\overset{1}{\rightleftharpoons}}$ ) ដើម្បីបង្ហាញថាប្រតិកម្មទៅមក ។

$$CuSO_4.5H_2O\ (s) \underset{2}{\overset{1}{\rightleftharpoons}} CuSO_4(s) + 5\ H_2O\ (g)$$

ប្រតិកម្មគីមីជាច្រើនជាប្រតិកម្មទៅមក ។

## ៣.២ បម្រែបម្រួលថាមពលក្នុងប្រតិកម្មទៅមក

នៅក្នុងប្រតិកម្មទី 1 ខាងលើនេះយើងត្រូវដុតកម្តៅក្រាមពណ៌ខៀវដើម្បីទទួលបានម្សៅពណ៌ស ដូចនេះប្រតិកម្មនេះជាប្រតិកម្មស្រូបកម្តៅ ។ នៅក្នុងប្រតិកម្មទី 2 ម្សៅពណ៌សឡើងក្តៅនៅពេលដែលយើងថែមទឹកទៅលើវា ប្រតិកម្មនេះជាប្រតិកម្មបញ្ចេញកម្តៅ ។ តាមពិតកម្តៅដែលវាបញ្ចេញស្មើនឹងកម្តៅដែលវាស្រូបនៅក្នុងប្រតិកម្មទី 1 ដែរ ។

*ប្រសិនបើប្រតិកម្មទៅមកជាប្រតិកម្មស្រូបកម្តៅតាមទិសដៅមួយ នោះវានឹងបញ្ចេញកម្តៅតាមទិសដៅមួយទៀត ហើយកម្តៅដែលស្រូបនិងបញ្ចេញមានបរិមាណស្មើគ្នា ។*

ដ្យាក្រាមកម្រិតថាមពល




## ៣.៣ ការបំបែកដោយកម្តៅរបស់អាម៉ូញ៉ូមក្លរួ

ការបំបែកដោយកម្តៅមានន័យថា ជាការបំបែកសមាសធាតុ មួយឱ្យទៅជាសមាសធាតុងាយផ្សេងទៀតដោយកម្តៅ ។

*ឧទាហរណ៍* ការបំបែកដោយកម្តៅរបស់អាម៉ូញ៉ូមក្លរួ

$$NH_4Cl\ (s) \underset{\text{ត្រជាក់}}{\overset{\text{ក្តៅ}}{\rightleftharpoons}} NH_3\ (g) + HCl\ (g)$$

ដ្យាក្រាមខាងស្តាំងនេះបង្ហាញថាមានអ្វីកើតឡើង ។



## ៤. ប្រតិកម្មទៅមក និង លំនឹងឌីណាមិច










សំណ II ក្លរួជាសមាសធាតុរលាយតិច ។ មានតែបរិមាណ 1,1 g ប៉ុណ្ណោះដែលអាចរលាយក្នុងទឹក 100 g

$PbCl_2(s) \rightarrow Pb^{2+}(aq) + 2Cl^-(aq)$

ប្រសិនបើយើងដាក់សំណ II ក្លរួបន្ថែមទៀត នោះវានឹងធ្លាក់ទៅបាតក្រោម ។

កាលណាយើងចុកឆ្នុក នោះវានឹងក្លាយទៅជាប្រព័ន្ធបិទជិត ។ អ៊ីយ៉ុងទាំងអស់ផ្លាស់ទីឥតឈប់ឈរពីអង្គធាតុរឹង ទៅសូលុយស្យុង និងពីសូលុយស្យុងទៅអង្គធាតុរឹងវិញ ។

ចលនានេះកើតឡើងក្នុងល្បឿនដូចគ្នានៅក្នុងទិសដៅទាំងពីរ ដូចនេះគ្មានសំណក្លរួណាអាចរលាយបានទៀតទេ យើងអាចពន្យល់ស្ថានភាពនេះតាមសមីការខាងក្រោម ÷

$PbCl_2(s) \rightleftharpoons Pb^{2+}(aq) + 2Cl^-(aq)$

នៅក្នុងកែវ អង្គធាតុរឹង និងសូលុយស្យុងឆ្អែតរបស់វាឈានដល់ភាព ***លំនឹងឌីណាមិច*** ( ជាទូទៅយើងហៅថាលំនឹង) ។

*លំនឹង* មានន័យថា គ្មានបម្រែបម្រួលទៀតទេ ។ ប៉ុន្តែពាក្យថា *ឌីណាមិច* មានន័យថា បម្រែបម្រួលកំពុងកើតឡើងឥតឈប់ឈរ ។ យើងអាចបង្ហាញបាតុភូតនេះដោយថែមសំណ II ក្លរួ ដែលរួមមានអ៊ីយ៉ុងវិទ្យុសកម្មរបស់សំណទៅក្នុងកែវខាងលើ ។ ដូចដែលយើងបានរំពឹងទុក អង្គធាតុរឹងនឹងធ្លាក់ចុះទៅបាតកែវ ។ បន្ទាប់ពីរយៈពេល ២០នាទីមក ម៉ាសរបស់វាស្ថិតនៅដដែល ប៉ុន្តែមានអ៊ីយ៉ុងសំណវិទ្យុសកម្មនៅក្នុងសូលុយស្យុង ។

ការរលាយគឺជាបម្រែបម្រួលរូប ។ ប៉ុន្តែបម្រែបម្រួលនេះកើតឡើងដូចគ្នាបេះបិទនៅក្នុងប្រតិកម្មគីមីទៅមក ។

*នៅក្នុងប្រព័ន្ធបិទជិត ទីបំផុត ប្រតិកម្មទៅមកនឹងឈានទៅដល់លំនឹងឌីណាមិច ។ ប្រតិកម្មទៅ និងប្រតិកម្មមកមានឡើងដោយល្បឿនស្មើគ្នា ដូច្នេះគ្មានបម្រែបម្រួលអ្វីកើតមានឡើងទេ ។*

## ៣.៥ លំនឹងឌីណាមិច និងឧស្សាហកម្ម




អាសូត អ៊ីដ្រូសែន និង អាម៉ូញាក់ក្នុងភាពលំនឹង ។ ល្បាយមានលំនឹង ។

នៅក្នុងឧស្សាហកម្មប្រតិកម្មសំខាន់ៗ ជាច្រើនជាប្រតិកម្មទៅមក ។

*ឧទាហរណ៍* ប្រតិកម្មរវាងអាសូត និង អ៊ីដ្រូសែនដើម្បីបង្កើតបានជាអាម៉ូញាក់ ។

$$N_2\,(g) + 3\,H_2\,(g) \rightleftharpoons 2NH_3(g)$$

ទីបំផុត ប្រតិកម្មនេះនឹងឈានដល់លំនឹងឌីណាមិច ដែលនៅពេលនោះម៉ូលេគុលអាម៉ូញាក់មួយចំនួនកើតឡើង ហើយម៉ូលេគុលអាម៉ូញាក់ដទៃទៀតបានបំបែក ។ ដូចនេះប្រតិកម្មមិនអាចឈាន ដល់កម្រិតមួយសព្វនោះទេ ។ នេះជាបញ្ហាចំពោះ

ក្រុមហ៊ុនដែលផលិតអាម៉ូញាក់។ ក្រុមហ៊ុនទាំងឡាយចង់បាននូវទិន្នផល ច្រើនតាមដែលអាចធ្វើបាន។ ដូចនេះតើគេត្រូវធ្វើដូចម្តេចដើម្បីទទង្វើអាម៉ូញាក់ឱ្យបានច្រើន?

**សំណួរ**

1. ដូចម្តេចដែលហៅថាប្រតិកម្មទៅមក ?
2. ចូរសរសេរសមីការតាងប្រតិកម្មទៅមករវាងទង់ដែងស៊ុលផាត និង ទឹក ?
3. តើលំនឹងឌីណាមិចមានន័យដូចម្តេច ?
4. ចូរពន្យល់ពីវិធីបង្កើតលំនឹងឌីណាមិចរវាងអំបិលសម្លូ និងទឹក ?

# ៤ បំលាស់ប្តូរលំនឹង

## ៤.១ ការផលិតអាម៉ូញាក់

នៅក្នុងរោងចក្រគេផលិតអាម៉ូញាក់ពីអាសូត និងអ៊ីដ្រូសែន។ ប្រតិកម្មនេះជាប្រតិកម្មទៅមក។

$N_2\,(g) + 3H_2\,(g) \rightleftharpoons 2\,NH_3\,(g)$

ចូរពិនិត្យមើលឱ្យបានច្បាស់ពីប្រតិកម្មនេះ ÷



អ៊ីដ្រូសែនពីរម៉ូលេគុលមានប្រតិកម្មជាមួយអាសូតមួយម៉ូលេគុលដើម្បីបង្កើតបានជាពីរម៉ូលេគុលអាម៉ូញាក់ ដូចនេះប្រសិនបើគេលាយបរិមាណត្រឹមត្រូវរវាងអាសូត និង អ៊ីដ្រូសែន ....

... តើវានឹងប្តូរទៅជាអាម៉ូញាក់ទាំងអស់ឬទេ? *ទេ*។ កាលណាបរិមាណជាក់លាក់ណាមួយរបស់អាម៉ូញាក់បាន កកើត ហើយនោះ ប្រព័ន្ធនឹងឈានដល់លំនឹងឌីណាមិច។ ដូចនេះ ....

...បើពីរម៉ូលេគុលអាម៉ូញាក់បានកើតឡើងនោះពីរម៉ូលេគុលទៀត បានបំបែកទៅជាអាសូត និងអ៊ីដ្រូសែនវិញ។ ដូចនេះបរិមាណអាម៉ូញាក់ដែល កកើតពុំផ្លាស់ប្តូរទេ។

កាលណាអាម៉ូញាក់កើតឡើងកាន់តែច្រើន នោះគេនឹងទទួលបានផលចំណេញកាន់តែច្រើន ដូចនេះតើគេអាចបង្កើនទិន្នផលបានយ៉ាងដូចម្តេច ?

គោលការណ៍ ឆាតឺលីយេ (Chatelier) *នៅពេលប្រតិកម្មទៅមកមួយឈានដល់កម្រិតលំនឹង របស់វាហើយបើយើងធ្វើឱ្យវាមានបម្រែ បម្រួលណាមួយ នោះប្រព័ន្ធនឹងឈានទៅរកលំនឹងថ្មី។*

យើងមិនអាចធ្វើឱ្យប្រតិកម្មទៅមកមួយប្រព្រឹត្តទៅសព្វបានទេ ។ វាតែងតែបញ្ចប់ក្នុងកម្រិតលំនឹងមួយ ។ ប៉ុន្តែដោយការផ្លាស់ប្តូរល័ក្ខខ័ណ្ឌ *យើងអាចរំកិលលំនឹងទៅខាងស្តាំ* ហើយអាចទទួល បានផលិតផលច្រើនថែមទៀត ។ ដូច្នេះតើយើងត្រូវធ្វើបម្រែបម្រួល ល័ក្ខខ័ណ្ឌអ្វីខ្លះដើម្បីទទួលបានទិន្នផលកាន់តែច្រើន?




ដូរលំនឹងទៅខាងស្តាំនាំឱ្យទទួលបានអាម៉ូញាក់ច្រើន ។

## ៤.១.១ ការបង្កើនសីតុណ្ហភាព

$$N_2 + 3H_2 \xrightarrow{\text{បញ្ចេញកម្តៅ}} 2NH_3$$

$$2NH_3 \xrightarrow{\text{ស្រូបកម្តៅ}} N_2 + 3H_2$$







យើងដឹងហើយថា កម្តៅអាចបង្កើនល្បឿនប្រតិកម្មគីមី ប៉ុន្តែក្នុងករណីនេះប្រតិកម្មទៅ ជាប្រតិកម្មបញ្ចេញកម្តៅ ។ ហើយប្រតិកម្មច្រាសមកវិញជាប្រតិកម្មស្រូបកម្តៅ ។

ប្រសិនបើយើងដុតកម្តៅល្បាយលំនឹង វានឹងប្រែប្រួល ។ ម៉ូលេគុលអាម៉ូញាក់ជាច្រើនត្រូវបានបំបែក ។

ជាលទ្ធផល ប្រតិកម្មនឹងឆាប់ឈានទៅដល់លំនឹង ដែលជាប្រការមួយល្អ ប៉ុន្តែកម្រិតអាម៉ូញាក់ *ថយចុះ*។ ដូចនេះលទ្ធផលទទួលបានកាន់តែតិច ជាងមុន ។

ប្រសិនបើយើងចង់បានទិន្នផលខ្ពស់ ដោយរក្សាសីតុណ្ហភាពទាប នោះយើងនឹងចំណាយពេលច្រើនដើម្បីឱ្យប្រតិកម្មនោះឈានដល់លំនឹង ។

## ៤.១.២. ការបង្កើនសម្ពាធ





4ម៉ូលេគុល 2ម៉ូលេគុល




សម្ពាធកើតឡើងដោយការទង្គិចរវាងម៉ូលេគុលឧស្ម័ន និងវត្ថុដែលផ្ទុកវា ។ ដូចនេះកាលណាវត្តមាននៃម៉ូលេគុលកាន់តែតិច នោះសម្ពាធក៏កាន់តែតូច ដែរ ។

ប្រសិនបើយើងបង្កើនសម្ពាធ ល្បាយលំនឹង នឹងប្រែប្រួល ។ ម៉ូលេគុលអាម៉ូញាក់នឹងកើតឡើងកាន់តែច្រើន ដើម្បីបន្ថយចំនួនម៉ូលេគុលឧស្ម័ន ។

ជាលទ្ធផល កម្រិតអាម៉ូញាក់ *កើនឡើង* ។ លំនឹងរំកិលទៅខាងស្តាំ ។

## ៤.១.៣. ការយកអាម៉ូញាក់ចេញ




ល្បាយលំនឹងគឺជាតុល្យការវាងកម្រិតអាសូត អ៊ីដ្រូសែន និងអាម៉ូញាក់ក្នុងប្រព័ន្ធ។ ប្រសិនបើយើងបញ្ចុះ សីតុណ្ហភាពល្បាយ នោះអាម៉ូញាក់នឹងកកមុនគេ។ ដូចនេះយើងអាចបង្ហូរយកវាបាន។ បន្ទាប់មកយើងដុតកម្តៅល្បាយ អាសូត និងអ៊ីដ្រូសែន ដែលនៅសល់ឡើងវិញ។ ក្នុងករណីនេះយើងទទួលអាម៉ូញាក់បន្ថែមទៀត។ នៅពេលដែលយើងយកអាម៉ូញាក់ ចេញ នោះអាសូត និងអ៊ីដ្រូសែនមានប្រតិកម្មជាមួយគ្នាដើម្បីទទួលបានលំនឹងជាថ្មី។

## ៤.១.៤ ការបន្ថែមកាតាលីករ

ក្នុងប្រតិកម្មសំយោគនេះ ដែកដើរតួជាកាតាលីករ។ ប៉ុន្តែ យើងត្រូវកត់សំគាល់ផងដែរថា វាបង្កើនទាំងល្បឿន ប្រតិកម្មទៅ និងប្រតិកម្មច្រាសមកវិញស្មើគ្នា។ ដូចនេះ ទោះបីជាប្រតិកម្មអាចឆាប់ឈានទៅដល់ភាពលំនឹងក៏ដោយ ក៏ទីតាំងរបស់លំនិងនេះពុំមានការផ្លាស់ប្តូរដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការប្រើកាតាលីករនៅតែជាការល្អដែរ ព្រោះវាចំណាយពេល និងថវិកាតិច។

### ការជ្រើសរើសលក្ខខណ្ឌសមស្រប

ដើម្បីឱ្យការផលិតចំណាយថវិកាអស់តិច យើងត្រូវពិចារណានូវកត្តាទាំងឡាយខាងលើ។ យើងត្រូវ ÷

- ប្រើសម្ពាធខ្ពស់ និងយកអាម៉ូញាក់ចេញ ដើម្បីរំកិលលំនឹងទៅខាងស្តាំ។
- ប្រើកាតាលីករដើម្បីឱ្យឆាប់ឈានដល់លំនឹង។
- ប្រើកម្តៅសមស្រប។

*សំគាល់* ចំពោះប្រតិកម្មទៅមកវាងឧស្ម័ន និង ឧស្ម័ន

បើប្រតិកម្មទៅជាលំនាំ ÷

- បញ្ចេញកម្តៅ *សីតុណ្ហភាពកើន នេះទិន្នផលថយ*
- ស្រូបកម្តៅ *សីតុណ្ហភាពកើន នោះទិន្នផលកើន*

បើមានម៉ូលេគុលអង្គធាតុកកើតតិចជាងអង្គធាតុប្រតិករ នៅក្នុងសមីការ ÷

-សម្ពាធកើន នោះទិន្នផលកើន

**សង្ខេបការផលិតអាម៉ូញាក់**

$$\underbrace{N_2\,(g) + 3H_2\,(g)}_{4\text{ ម៉ូលេគុល}} \rightleftharpoons \underbrace{2\,NH_3\,(g)}_{2\text{ ម៉ូលេគុល}}$$

**ដើម្បីង្កើនទិន្នផល យើងត្រូវ** ÷

- ប្រើសម្ពាធខ្ពស់
- ប្រើសីតុណ្ហភាពទាប
- យកអាម៉ូញាក់ចេញ

**ដើម្បីទទួលបានល្បឿនប្រតិកម្មសមស្រប យើងត្រូវ** ÷

- បង្កើនសីតុណ្ហភាព (ទៅតាមតម្រូវការ)
- ប្រើកាតាលីករ

**សំណួរ**

1. ចូរពន្យល់ថាមានអ្វីកើតឡើងនៅក្នុងល្បាយលំនឹងនៃអាសូត អ៊ីដ្រូសែន និងអាម៉ូញាក់។
   ហេតុអ្វីបានជាបញ្ហានេះ បង្កផលវិបាកដល់ឧស្សាហកម្ម?
2. ចូរនិយាយពីគោលការណ៍ ឆាតឺលីយេ?
3. នៅក្នុងការផលិតអាម៉ូញាក់ ចូរពន្យល់ថាហេតុអ្វី ÷
   ក- គេប្រើសម្ពាធខ្ពស់?
   ខ- គេយកអាម៉ូញាក់ចេញ?
   គ- គេប្រើកម្ដៅសមស្រប?
4. ស្ពាន់ធ័រឌីអុកស៊ីតមានប្រតិកម្មជាមួយអុកស៊ីសែនដើម្បីបង្កើតបានជាស្ពាន់ធ័រទ្រីអុកស៊ីត។ ប្រតិកម្មនេះជាប្រតិកម្មបញ្ចេញកម្ដៅ ហើយជាប្រតិកម្មទៅមក។
   ក- ចូរសរសេរសមីការលំនឹងសម្រាប់ប្រតិកម្មនេះ។
   ខ- តើទិន្នផលរបស់ស្ពាន់ធ័រទ្រីអុកស៊ីតប្រែប្រួលយ៉ាងដូចម្ដេច ÷
      (i) ប្រសិនបើគេបង្កើនសម្ពាធ។
      (ii) ប្រសិនបើគេបង្កើនសីតុណ្ហភាព។

# ៥ ផលិតកម្មអាម៉ូញាក់ក្នុងឧស្សាហកម្ម

អាម៉ូញាក់ជាសារធាតុគីមីដែលសំខាន់ទូទាំងពិភពលោកក្នុងចំណោមសារធាតុគីមីទាំងឡាយ ព្រោះគេត្រូវការវាដើម្បីផលិតជីគីមី។ កាលពី 100 ឆ្នាំមុន នៅអឺរ៉ុប ខ្វះជីធម្មជាតិសម្រាប់ការប្រើប្រាស់។ ប្រសិនបើគេអាចផលិតអាម៉ូញាក់ពីអាសូតនៅក្នុងខ្យល់បាន គេនឹងអាចដោះស្រាយបញ្ហានេះ។ ប៉ុន្តែវាមិនមែនជាការពងាយស្រួលទេ។ អាសូតជាធាតុអសកម្ម ហើយប្រតិកម្ម របស់វាជាមួយអ៊ីដ្រូសែនជាប្រតិកម្មទៅមកទៀត។

នៅឆ្នាំ ១៩០៨ គីមីវិទូជនជាតិអាឡឺម៉ង់ឈ្មោះ ហ្វ្រីត្ស ហែប៊ឺ (Fritz Haber) បានអភិវឌ្ឍលំនាំមួយដែលអាចដំណើរការបាន។ បន្ទាប់ពីគាត់ស្លាប់ទៅ គេបានយកឈ្មោះគាត់មកដាក់ឈ្មោះលំនាំនេះ ហើយត្រូវបានគេប្រើប្រាស់ទូទាំងពិភពលោក។

## ៥.២ លំនាំហែប៊ឺ (Haber Process) ក្នុងការផលិតអាម៉ូញាក់

1. វត្ថុធាតុដែលគេយកមកប្រើដើម (អាសូត និងអ៊ីដ្រូសែន) ត្រូវបានលាយបញ្ចូលគ្នា។
2. គេបណ្ណែនល្បាយឧស្ម័ននេះរហូតដល់ទទួលបានសំពាធ 200 atm។
3. បន្ទាប់មកល្បាយឧស្ម័ននេះត្រូវបញ្ជូនទៅក្នុងឧបករណ៍បំលែងឧស្ម័ន ដែលជាធុងមូល និងមានថ្នេរដាក់កម្ទេចដែកក្ដៅប្រហែល 450 $^{o}$C នៅក្នុងនោះ។ ដែកដើរតួជាកាតាលីករក្នុងប្រតិកម្មនេះ។
   $N_2\,(g) + 3H_2\,(g) \rightleftharpoons 2NH_3\,(g)$
   ល្បាយឧស្ម័នដែលបានឆ្លងកាត់ឧបករណ៍បំលែងមានអាម៉ូញាក់ប្រហែល 15% ប៉ណ្ណោះ។

4.បន្ទាប់មកគេបញ្ចុះសីតុណ្ហភាពល្បាយនេះរហូតដល់អាម៉ូញាក់ក្លាយជាអង្គធាតុរាវ ។ អាសូត និងអ៊ីដ្រូសែនដែលនៅសល់ត្រូវបានប្រើម្តងទៀត ដោយបញ្ជូនវាត្រឡប់ទៅក្នុងឧបករណ៍បំលែងឧស្ម័ន ដើម្បីឱ្យវាមានឱកាសធ្វើប្រតិកម្មម្តងទៀត ។ ដំណាក់កាលទី 3 និងទី 4 ត្រូវដំណើរការដដែលៗឡើងវិញ ។

5. គេបង្ហូរអាម៉ូញាក់ទៅក្នុងធុង ដោយរក្សាវាក្នុងភាពជាអង្គធាតុរាវ ក្រោមឥទ្ធិពលនៃសម្ពាធ ។




## វត្ថុធាតុដើម

### អាសូត

ក្នុងខ្យល់មានបរិមាណអាសូត $4/5$ អុកស៊ីសែនប្រមាណ $1/5$ ហើយនិងមានបរិមាណតិចតួចនៃឧស្ម័នដទៃទៀត ។
គេអាចបំបាត់អុកស៊ីសែនចេញពីខ្យល់ដោយការដុតអ៊ីដ្រូសែននៅក្នុងខ្យល់ ។

$$2H_2(g) + O_2(g) \longrightarrow 2H_2O\ (l)$$

ប្រតិកម្មនេះធ្វើឱ្យខ្យល់ដែលនៅសល់ស្ទើរតែជាបរិមាណអាសូតទាំងអស់ ។

### អ៊ីដ្រូសែន

ជាធម្មតាគេទទួលវាបានពីឧស្ម័នធម្មជាតិ ឬ មេតាន ប្រតិកម្មជាមួយទឹក (ចំហាយ) ។

$$CH_4(g) + 2\ H_2O\ (g) \xrightarrow{\text{កាតាលីករ}} CO_2(g) + 4H_2\ (g)$$

គេក៏អាចបំបែកសមាសធាតុនៅក្នុងប្រេង ឱ្យទៅជាអ៊ីដ្រូសែនបានដែរ ។ ដូចជា ÷

$$C_2H_6(g) \xrightarrow{\text{កាតាលីករ}} C_2H_4(g) + H_2(g)$$

# ៥.៣ ការផលិតអាម៉ូញាក់ដោយសន្សំសំចៃ

ជាធម្មតារោងចក្រផលិតអាម៉ូញាក់អាចផលិតបាន 1200 តោនអាម៉ូញាក់រាវក្នុងមួយថ្ងៃ។ ក្រុមហ៊ុនព្យាយាមរកវិធីដើម្បីឱ្យបានចំណេញច្រើន ដូចនេះគេត្រូវកាត់បន្ថយការចំណាយតាមដែលអាចធ្វើបាន

## ៥.៣.១ ការជ្រើសរើសសីតុណ្ហភាព និងសម្ពាធ

ក្រាបនេះបង្ហាញពីបម្រែបម្រួលទិន្នផលអាម៉ូញាក់ទាក់ទងទៅនឹងសម្ពាធ និងសីតុណ្ហភាព។ ដើម្បីបានទិន្នផលខ្ពស់បំផុត យើងគួរតែជ្រើសរើសសីតុណ្ហភាព 350 °C និងសម្ពាធ 400 atm (សូមមើលចំណុច X នៅលើក្រាប)។ តែរោងចក្របានជ្រើសរើសយកសម្ពាធ 200 atm និង សីតុណ្ហភាព 450 °C ។ ហេតុអ្វី ?

ទិន្នផលអាម៉ូញាក់នៅសំពាធ និង សីតុណ្ហភាពខុសៗគ្នា




ដើម្បីបង្កើនសម្ពាធដល់ឧស្ម័ន យើងត្រូវបណ្ណែនវាទៅក្នុងធុងដែលកាន់តែតូច។ ប្រការនេះយើងត្រូវចំណាយលុយអស់យ៉ាងច្រើន ព្រោះយើងត្រូវការម៉ាស៊ីនបូម ដែលខ្លាំងហើយត្រូវការប្រើកម្លាំងអគ្គិសនីអស់ច្រើន។ ហេតុដូចនេះហើយបានជាគេជ្រើសរើសយកសម្ពាធ 200 atm ពីព្រោះគេអាចសន្សំប្រាក់ចំណាយ។ យើងគួរកត់សំគាល់ផងដែរថា បំពង់ឧបករណ៍បំលែងឧស្ម័ន និងធុងដទៃទៀតត្រូវតែរឹងមាំខ្លាំងដើម្បីធន់ជាមួយនឹងសម្ពាធនេះ។

នៅសីតុណ្ហភាព 350 °C ប្រតិកម្មនេះផ្តល់ទិន្នផលល្អបំផុត ប៉ុន្តែល្បឿនរបស់ប្រតិកម្ម**យឺតណាស់** ហេតុដូចនេះហើយនៅពេលដែលយើងចង់ផលិតអាម៉ូញាក់ 1200 តោនក្នុងមួយថ្ងៃ គេបានដំឡើងសីតុណ្ហភាពរហូតដល់ 450 °C ដើម្បីជួយសម្រួលដល់ការផលិតនេះ។

ដោយសារតែមូលហេតុខាងលើនេះហើយ បានជាល័ក្ខខ័ណ្ឌនៅក្នុងឧបករណ៍បំលែងមិនត្រូវបានគេជ្រើសរើសយកល័ក្ខខ័ណ្ឌដែលទទួលបានទិន្នផលខ្ពស់បំផុតទេ។ ប៉ុន្តែក្នុងករណីដែលយើងជ្រើសរើសនេះគឺមានលក្ខណៈប្រសើរជាង ពីព្រោះគេអាចប្រើឧស្ម័នដែលមិនបានចូលរួមប្រតិកម្មឡើងវិញ។

## ៥.៣.២ កាតាលីករ

កាតាលីករទាំងអស់នឹងខូចនៅចុងបញ្ចប់នៃប្រតិកម្មដោយសារមានធាតុមិនសុទ្ធ ដូច្នេះដើម្បីពន្យឺតដល់ការខូចខាតនេះ គេបន្ថែមសមាសធាតុដទៃទៀតទៅលើកាតាលីករដែក។ ទោះបីជាយ៉ាងណានេះក៏ដោយ ក៏គេត្រូវផ្លាស់វាជារៀងរាល់ពីរបីឆ្នាំម្តងដែរ។ គីមីវិទូទាំងឡាយកំពុងតែព្យាយាមបង្កើនដល់ប្រសិទ្ធភាពរបស់កាតាលីករ។

## ៥.៣.៣ អង្គធាតុដើម

ជាការល្អដែរដែលយើងអាចទទួលបានខ្យល់ និងទឹកយ៉ាងងាយស្រួល។ ប៉ុន្តែយើងក៏ត្រូវការឧស្ម័នធម្មជាតិដែរ (មេតាន) ឬ សមាសធាតុពីប្រេង ដើម្បីផលិតអ៊ីដ្រូសែន។ ហេតុនេះ រោងចក្រផលិតអាម៉ូញាក់បានទាក់ទងជាមួយនឹង

រោងចក្រចម្រាញ់ប្រេងដើម្បីទទួលយកសមាសធាតុដែលអាចបំបែកជាអ៊ីដ្រូសែនបាន។ តាមពិតក្រុមហ៊ុនប្រេង និងឧស្ម័នជាច្រើនផលិតអាម៉ូញាក់ដែលជាវិធីមួយគេអាចបង្កើននូវប្រាក់ចំណេញរបស់គេ។

### សំណួរ

1. គេផលិតអាម៉ូញាក់ពី អាសូត និងអ៊ីដ្រូសែន។

   ក- តើគេអាចទទួលបានអ៊ីដ្រូសែន និងអាសូត តាមវិធីណា?

   ខ- តើលំនាំទង្វើអាម៉ូញាក់មានឈ្មោះអ្វី?

   គ- តើក្នុងលំនាំនេះគេប្រើកាតាលីករអ្វី?

   ឃ- ចូរសរសេរសមីការសម្រាប់ប្រតិកម្មនេះ?
2. ចូរមើលគំនូសតាងនៃការផលិតអាម៉ូញាក់។ ហេតុអ្វីបានជានៅក្នុងឧបករណ៍បំលែងឧស្ម័នគេតម្រៀបធ្នើរដាក់កាតាលីករក្នុងរបៀបដូច្នោះ?
3. កាលណាគេប្រើសម្ពាធ 400 atm និង សីតុណ្ហភាព 350 $^{o}$C នោះគេនឹងទទួលបានទិន្នផលច្រើនបំផុត។ ចូរពន្យល់ថាហេតុអ្វីបានជាគេប្រើសម្ពាធត្រឹមតែ 200 atm និងសីតុណ្ហភាព 450 $^{o}$C?

# ៦ ដី

## ៦.១ តម្រូវការរបស់រុក្ខជាតិ

តើរុក្ខជាតិត្រូវការអ្វី?

រុក្ខជាតិត្រូវការ កាបូនឌីអុកស៊ីត ពន្លឺ និងទឹក។ វាក៏ត្រូវការធាតុគីមីដទៃទៀតដែរ ជាពិសេសគឺ **អាសូត** (N) **ផូស្វរ**(P) និង**ប៉ូតាស្យូម**(K)។



រុក្ខជាតិត្រូវការអាសូតដើម្បីបង្កើតនូវប្រូតេអ៊ីនសម្រាប់ឱ្យដើមរបស់វារឹងមាំ និងមានស្លឹកល្អ។



ប៉ូតាស្យូមជួយរុក្ខជាតិទប់ទល់នឹងសំណើមកក និងប្រឆាំងជំងឺផ្សេងៗ។



រុក្ខជាតិត្រូវការផូស្វរដើម្បីឱ្យឫស ឬមើម វាលូតលាស់ ហើយក៏ជួយឱ្យគ្រាប់រុក្ខជាតិទុំ។

រុក្ខជាតិទាំងឡាយទទួលបានធាតុទាំងនេះពីសមាសធាតុនៅក្នុងដី ដែលវាអាចស្រូបយកតាមរយៈឫសក្នុងភាពជាសូលុយស្យុង។ ធាតុគីមីដែលសំខាន់ជាងគេបំផុតសម្រាប់រុក្ខជាតិគឺ **អាសូត** ព្រោះគ្រប់កោសិការុក្ខជាតិទាំងអស់ត្រូវការប្រូតេអ៊ីន។ រុក្ខជាតិស្រូបយកអាសូតក្នុងទម្រង់ជាអ៊ីយ៉ុង **នីត្រាត** និង អ៊ីយ៉ុង **អាម៉ូញ៉ូម**។

## ៦.២ ជីគីមី

គ្រាប់ធញ្ញជាតិដែលកសិករដាំទាំងអស់សុទ្ធតែស្រូបយកសមាសធាតុពីក្នុងដី ហើយសមាសធាតុទាំងនេះក៏អាចជំនួសមកវិញដោយធម្មជាតិដែរ។

*ឧទាហរណ៍*

- ផ្លេកបន្ទោរអាចធ្វើឱ្យអាសូត និងអុកស៊ីសែនមានប្រតិកម្មជាមួយគ្នាដើម្បីបង្កើតបានជាអាសូតអុកស៊ីត។ អាសូតអុកស៊ីតទាំងនេះរលាយក្នុងទឹកភ្លៀងបង្កើតបានជាភ្លៀងអាស៊ីត ដែលអាចមានប្រតិកម្មជាមួយសមាសធាតុក្នុងដីបង្កើតបានជានីត្រាត។
- លាមកសត្វមាននីត្រាតមួយចំនួន និងប្រូតេអ៊ីនដែលអាចបំបែកនៅក្នុងដីឱ្យទៅជាសមាសធាតុអាម៉ូញ៉ូម។ វាក៏ អាចជួយផ្ដល់ធាតុប៉ូតាស្យូម និងផូស្វ័រទៅក្នុងដីផងដែរ។
- បាក់តេរីមួយចំនួនអាចជួយស្រូបយកអាសូតបាន។ វាអាចបំលែងអាសូតនៅក្នុងខ្យល់ឱ្យទៅជានីត្រាត។ បាក់តេរីនេះរស់នៅក្នុងដី និងនៅក្នុងកំពកឫសដូចជានៅក្នុង ឫសសណ្ដែក និងរុក្ខជាតិដែលមានឫសជាកំពក។

ប៉ុន្តែជីដែលទទួលបានពីធម្មជាតិទាំងនេះ មិនអាចបំពេញតម្រូវការស្រូបយករបស់រុក្ខជាតិបានគ្រប់គ្រាន់ទេ។ ដូច្នេះរុក្ខជាតិមិនសូវបានផលល្អទេប្រសិនបើគេមិនបន្ថែមជីគីមីដូចខាងក្រោមនេះ។

*អាម៉ូញ៉ូមនីត្រាត* $NH_4NO_3$ *អាម៉ូញ៉ូមស៊ុលផាត* $(NH_4)_2SO_4$

*ប៉ូតាស្យូមស៊ុលផាត* $K_2SO_4$ *អាម៉ូញ៉ូមផូស្វាត* $(NH_4)_3PO_4$

*សំគាល់* ជី NKP រួមមានអាសូត N ប៉ូតាស្យូម K និង ផូស្វ័រ P

*ជីគីមីគឺជាសមាសធាតុទាំងឡាយណាដែលបន្ថែមទៅក្នុងដីដើម្បីឱ្យដីកាន់តែមានជីជាតិ។* ជីគីមីខាងលើនេះត្រូវបានគេផលិតវាក្នុងរោងចក្រហើយច្រកចូលបាវដើម្បីងាយស្រួលដឹកជញ្ជូន។ ជីគីមីចំនួនបីប្រភេទក្នុងចំណោមជីគីមីខាងលើនេះផ្ដល់អាសូត ដូចនេះគេឱ្យឈ្មោះជីទាំងនោះថា**ជីអាសូត។** ជីទាំងអស់នោះគឺជាអំបិលដែលគេផលិតវាដោយធ្វើប្រតិកម្មបន្សាបទៅលើអាស៊ីត។

## ៦.៣ សារៈសំខាន់នៃអាម៉ូញាក់ក្នុងឧស្សាហកម្មជីអាសូត

ក្នុងខ្យល់សំបូរទៅដោយអាសូត ប៉ុន្តែរុក្ខជាតិមិនអាចស្រូបយកអាសូតពីក្នុងខ្យល់បានច្រើនដូចពីក្នុងដីនោះទេ។ លំនាំហ៊ែប៊ឺរផ្ដល់ឱ្យយើងនូវវិធីមួយដើម្បីទាញយកអាសូតពីខ្យល់ទៅក្នុងរោងចក្រ។ ជាទូទៅរុក្ខជាតិស្រូបយកអាសូតក្នុងទម្រង់ជាអ៊ីយ៉ុងនីត្រាតបានល្អជាងក្នុងទម្រង់អ៊ីយ៉ុងអាម៉ូញ៉ូម។ អាម៉ូញាក់ជាប្រភេទគីមីដ៏សំខាន់ក្នុងការផលិតអាស៊ីតនីទ្រិចដែលត្រូវបានបំលែងទៅជាអំបិលនីត្រាត។

## ៦.៣.១ ការបំលែងពីអាម៉ូញាក់ទៅអាស៊ីតនីទ្រិច

អាម៉ូញាក់ $NH_3$

↓

1. **1.** លាយជាមួយខ្យល់
2. **2.** ឱ្យឆ្លងកាត់កាតាលីករដែលដុតកម្ដៅ
   (សំណាញ់ប្លាទីន/រូដ្យូម)

អាសូតម៉ូណូអុកស៊ីត NO

$$4NH_3\,(g) + 5\,O_2\,(g) \longrightarrow 4\,NO\,(g) + 6\,H_2O\,(g)$$

↓

3. **3.** បញ្ចុះសីតុណ្ហភាព
4. **4.** បន្ថែមខ្យល់

អាសូតឌីអុកស៊ីត $NO_2$

$$2\,NO\,(g) + O_2(g) \longrightarrow 2\,NO_2(g)$$

↓

5. **5.** បន្ថែមខ្យល់
6. **6.** លាយជាមួយទឹក

អាស៊ីតនីទ្រិច $HNO_3$

$$4NO_2(g) + O_2(g) + 2H_2O\,(l) \longrightarrow 4\,HNO_3(aq)$$

លទ្ធផលសរុបគឺអាម៉ូញាក់ធ្វើអុកស៊ីតកម្មទៅជាអាស៊ីតនីទ្រិច ។

## ៦.៣.២ ការបំលែងអាស៊ីតនីទ្រិចទៅជាអំបិលនីត្រាត

អាម៉ូញ៉ូមនីត្រាតគឺជាជីសមញ្ញបំផុតមួយប្រភេទ ។ គេផលិតវាដោយធ្វើប្រតិកម្មបន្សាបរវាងអាស៊ីតនីទ្រិច និងសូលុយស្យុងអាម៉ូញាក់ ។

$$HNO_3(aq) \quad + \quad NH_3(aq) \longrightarrow NH_4NO_3\,(aq)$$

អាស៊ីតនីទ្រិច អាម៉ូញាក់ អាម៉ូញ៉ូមនីត្រាត

គេក៏ធ្វើអាម៉ូញ៉ូមស៊ុលផាតតាមវិធីស្រដៀងគ្នានេះដែរ ។

$$H_2SO_4(aq) \quad + \quad 2NH_3(aq) \longrightarrow (NH_4)_2SO_4\,(aq)$$

អាស៊ីតស៊ុលផួរិច អាម៉ូញាក់ អាម៉ូញ៉ូមស៊ុលផាត

### សំណួរ

1. ចូរប្រាប់ឈ្មោះធាតុគីមីចំនួនបីដែលរុក្ខជាតិត្រូវការពីដី ។ ហេតុអ្វីបានជារុក្ខជាតិត្រូវការធាតុទាំងបីនេះ?
2. ចូររៀបរាប់វិធីធម្មជាតិពីរយ៉ាងដែលអាសូតនៅក្នុងខ្យល់បំលែងទៅជាអំបិលនីត្រាតនៅក្នុងដី ។
3. តើជីគឺជាអ្វី? ហេតុអ្វីបានជាគេត្រូវការវា?
4. ហេតុអ្វីបានជាគេថា លាមកសត្វគឺជាជីធម្មជាតិ ។ ចូរពន្យល់ ។

5. ចូរប្រាប់ឈ្មោះជីអាសូតចំនួនបី?

6. ហេតុអ្វីបានជាលំនាំ ហ៊ែប៊ឺរ មានសារៈសំខាន់ចំពោះការដាំដុះ ?

7. ក- ក្នុងប្រតិកម្មបំលែងពីអាម៉ូញាក់ទៅអាស៊ីតនីទ្រិច

   (i) ចូរប្រាប់ឈ្មោះវត្ថុធាតុដើមចំនួនបី

   (ii) តើគេប្រើកាតាលីករអ្វី ?

   ខ- ជាសរុបអាម៉ូញាក់ត្រូវរងអុកស៊ីតកម្ម ។ តើពាក្យអុកស៊ីតកម្មមានន័យដូចម្តេច ?

8. ចូរសរសេរសមីការលំនឹងនៃប្រតិកម្មផលិតជីអាម៉ូញ៉ូមនីត្រាត ។

# ៧ ការគាំទ្រ និងការប្រឆាំងការប្រើប្រាស់ជី

## ៧.១ បដិវត្តបៃតង

កាលពី 100 ឆ្នាំមុន កសិករភាគច្រើនធ្វើការដាំដុះជាលក្ខណៈគ្រួសារមានទ្រង់ទ្រាយតូចតាច ។ ពួកគេប្រើលាមកសត្វ និងកាកសំណល់ផ្ទះបាយជាជី ។ នៅពេលមានការវិវត្តខាងម៉ាស៊ីន ពួកគេអាចធ្វើការដាំដុះបានយ៉ាងមានប្រសិទ្ធភាពដែលធ្វើឱ្យទិន្នផលស្បៀងកើនឡើង ប៉ុន្តែមានលក្ខណៈយឺត ។

នៅឆ្នាំ១៩១៣ គេបានបង្កើតរោងចក្រផលិតអាម៉ូញាក់ដំបូងនៅប្រទេសអាឡឺម៉ង់ ដោយប្រើលំនាំ ហ៊ែប៊ឺ ហើយនៅពេលនោះបដិវត្តនៃការដាំដុះក៏បានចាប់ផ្តើមផងដែរ ហើយបដិវត្តនេះបានចាប់ផ្តើមយ៉ាងយឺតៗ ។ នៅពេលដែលសង្គ្រាមលោកលើកទី១ផ្ទុះឡើង អាម៉ូញាក់ទាំងអស់ត្រូវបានប្រើសម្រាប់ផលិតគ្រឿងផ្ទុះ ។ បុព្វហេតុនេះបានធ្វើឱ្យសេដ្ឋកិច្ច ទូទាំងពិភពលោកមានការធ្លាក់ចុះ ។ បន្ទាប់មកសង្គ្រាមលោកលើកទី២បានកើតឡើង ហើយម្តងនេះផលិតកម្មអាម៉ូញាក់ក៏ត្រូវប្តូរទៅជាផលិតកម្មសព្វាវុធវិញ ។ ប៉ុន្តែបន្ទាប់ពីសង្គ្រាមលោកលើកទី២មក ការផលិតជីគីមីបានចាប់ផ្តើមដំណើរការឡើងវិញ ហើយទិន្នផលគ្រាប់ធញ្ញជាតិក៏កើនឡើងដែរក្នុងមួយហិកតា ។

បុព្វហេតុនៃការកើនឡើងនេះគឺដោយសារការរីកចម្រើននៃគ្រឿងម៉ាស៊ីន និងគ្រាប់ពូជ ប៉ុន្តែភាគច្រើនគឺបណ្តាលមកពីការប្រើប្រាស់ជីគីមី ។

## ៧.២ ការផ្គត់ផ្គង់ពិភពលោក

ចូរគិតមើលថាតើប្រជាជននៅទូទាំងពិភពលោកមានកំណើនយ៉ាងដូចម្តេចក្នុងអំឡុងឆ្នាំ 1900 ដល់ឆ្នាំ 2000 ។ តើគេផ្គត់ផ្គង់ស្បៀងដល់ប្រជាជនទាំងអស់នោះយ៉ាងដូចម្តេច? ដីដែលមានសម្រាប់ការដាំដុះពុំមានការផ្លាស់ប្តូរច្រើននោះ ទេ តែអ្វីដែលធ្វើឱ្យមានការផ្លាស់ប្តូរនោះគឺការប្រើប្រាស់ជី ។ គេបានប៉ាន់ប្រមាណថា 40 % នៃប្រជាជន ប្រហែល 6 កោដិនាក់ ដែលរស់នៅសព្វថ្ងៃនេះបានអរគុណដល់លំនាំ ហ៊ែប៊ឺរ ។

បច្ចុប្បន្ននេះពិភពលោកបានផលិតស្បៀងលើសពីតម្រូវការ ។ នៅឆ្នាំ 1998 គេបានផលិតស្បៀងភាពគ្រប់គ្រាន់សម្រាប់មនុស្សប្រហែល 6,9 កោដិនាក់ ។ ប្រជាជនបច្ចុប្បន្នមានចំនួនតិចជាង 6 កោដិនាក់ប៉ុន្តែនៅតែមានមនុស្សជាច្រើន

ដែល មិនទាន់មាន ស្បៀងគ្រាប់គ្រាន់សម្រាប់ទទួលទាន ។ ប្រទេសក្រីក្រមួយចំនួនផលិត ស្បៀងមិនបានគ្រប់គ្រាន់ទេ ពីព្រោះកសិករមិនអាចទិញជីបាន ឬមិន មានគ្រាប់ពូជល្អ ឬគ្មានគ្រឿងម៉ាស៊ីនសម្រាប់ប្រើប្រាស់ ហើយភ្លៀង ធ្លាក់ក៏មិនគ្រប់គ្រាន់ ។ ប្រទេសដទៃទៀតផលិតស្បៀងលើសពីតម្រូវការ ។ ដូចនេះការផលិតស្បៀងនៅលើពិភពលោកមិនមានលក្ខណៈស្មើគ្នាទេ ។

គេគិតថារហូតដល់ឆ្នាំ 2025 មនុស្សនឹងកើនដល់ប្រហែល 8,3 កោដិនាក់ ដូច្នេះប្រសិនបើគ្មានជីទេនោះ ការផលិត ស្បៀងនឹងមិនបានគ្រប់គ្រាន់ឡើយ ។

*ប្រជាជនពិភពលោកឆ្នាំ ១៩០០-២០០០*




## ៧.៣ ផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់ជី

នៅពេលគេបាចជីទៅក្នុងស្រែ វាមិនត្រឹមតែស្រូបយកដោយឬសរុក្ខជាតិតែប៉ុណ្ណោះទេ ។ ចូរពិនិត្យមើលរូបភាពខាងក្រោម ÷




### ៧.៣.១ ការខ្វះខាតអុកស៊ីសែនក្នុងទឹក

**សារ៉ាយ**ជារុក្ខជាតិតូចៗដែលរស់នៅលើទឹក ។ ជីអាចជួយឱ្យរុក្ខជាតិនេះលូតលាស់បានយ៉ាងល្អ ។ វាអណ្តែតនៅលើផ្ទៃទឹកដូចជាកម្រាលព្រំដែរ ដែលរំខានដល់ការធ្វើរស្មីសំយោគរបស់រុក្ខជាតិនៅក្រោមទឹកដោយរាំងពន្លឺព្រះអាទិត្យ ។ នៅពេលរុក្ខជាតិនៅក្នុងទឹកងាប់ វានឹងរលួយដោយសារការបំបែករបស់បាក់តេរី ហើយលំនាំនេះប្រព្រឹត្តទៅដោយប្រើប្រាស់អុកស៊ីសែននៅក្នុងទឹក ។ ប្រការនេះអាចឱ្យសត្វក្នុងទឹកស្លាប់ដោយសារតែខ្វះខាតអុកស៊ីសែន ។

### ៧.៣.២ ជំងឺខាន់លឿងចំពោះកូនក្មេង

ពោះវៀនរបស់យើងអាចបំលែងអ៊ីយ៉ុងនីត្រាតទៅជានីទ្រីត ហើយវាអាចចូលផ្សំជាមួយអេម៉ូក្លូប៊ីន ដែលជាហេតុធ្វើឱ្យឈាមរបស់យើងមិនអាចដឹកនាំអុកស៊ីសែនបានគ្រប់គ្រាន់ទៅឱ្យសារពាង្គកាយ។ បញ្ហានេះអាចបណ្តាលសារពាង្គកាយខ្វះអុកស៊ីសែន (ភាគច្រើនកើតចំពោះកូនក្មេង) ដែលជាហេតុធ្វើឱ្យស្បែករបស់គេមានស្នាមពណ៌ខៀវព្រឿងៗ។ ជំងឺនេះធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់គេ តែជាធម្មតាមិនធ្វើឱ្យគេស្លាប់ទេ។

កំហាប់នីត្រាតខ្ពស់នៅក្នុងទឹកសម្រាប់បរិភោគក៏ទាក់ទងនឹងជំងឺមហារីកដែរ ប៉ុន្តែទំនាក់ទំនងនេះមិនទាន់មាននរណាម្នាក់អាចបង្ហាញបាននៅឡើយទេ។

## ៧.៤ ដំណោះស្រាយបញ្ហាបំពុលបរិស្ថាន

កសិករអាចជួយបញ្ហានេះបានដោយប្រើជីតិចតួច ហើយកុំប្រើវានៅលើដីសើម ឬនៅក្នុងអាកាសធាតុសើម។ ចំពោះទឹកបរិភោគ យើងអាចបំបាត់អ៊ីយ៉ុងនីត្រាតនៅកន្លែងផលិតទឹក ប៉ុន្តែការស្វែងរកប្រភពទឹកស្អាតគឺជាវិធីមួយដែលចំណាយប្រាក់អស់តិចជាង។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានរុក្ខជាតិមួយចំនួនបានប្រើប្រាស់បាក់តេរីដើម្បីស្រូបយកអ៊ីយ៉ុងនីត្រាតចេញពីទឹក។ វិធីនេះត្រូវបានគេប្រើជាទូទៅនៅអឺរ៉ុប ដែលបន្ទាប់មកគេអាចសម្លាប់បាក់តេរីដោយប្រើក្លរ។

មានមនុស្សមួយចំនួនជឿជាក់ថា ការដាំដុះតាមបែបធម្មជាតិគឺជាវិធីមួយល្អបំផុត ដែលក្នុងនោះកសិករប្រើតែជីធម្មជាតិ និងធ្វើការផ្លាស់ប្តូរប្រភេទដំណាំដែលគាត់ដាំដុះ ឬទុកដីឱ្យនៅទំនេរ ដើម្បីឱ្យដីមានជីជាតិដោយធម្មជាតិឡើងវិញ។

**សំណួរ**

1. គេបានប៉ាន់ប្រមាណថា ប្រជាជនប្រហែល 40% នៃប្រជាជនទូទាំងពិភពលោកអរគុណចំពោះលំនាំហ៊ែប៊ឺរ។ ចូរពន្យល់ ?
2. តើនៅក្នុងទន្លេដែលមានរុក្ខជាតិតូចៗនៅលើផ្ទៃទឹក អ្នកសង្ស័យថានឹងមានអ្វីកើតឡើង?
3. ចូររៀបរាប់ពីបញ្ហាសុខភាពដែលទាក់ទងទៅនឹងការប្រើប្រាស់ជី?
4. ដូចម្តេចដែលហៅថាការដាំដុះតាមបែបធម្មជាតិ? តើការដាំដុះតាមបែបធម្មជាតិអាចចិញ្ចឹមប្រជាជនទូទាំងពិភពលោកបានដែរឬទេ? ហេតុអ្វី?

# សំណួរសម្រាប់មេរៀនទី ៩

1. សមីការតាងប្រតិកម្មរវាងសូដ្យូមអ៊ីដ្រុកស៊ីត និងអាស៊ីតក្លរីឌ្រិច

$$NaOH\ (aq) + HCl\ (aq) \longrightarrow NaCl\ (aq) + H_2O\ (l)$$

ប្រតិកម្មនេះបញ្ចេញកម្តៅ។

ក- តើសីតុណ្ហភាពរបស់សូលុយស្យុងប្រែប្រួលដូចម្តេចនៅពេលមានប្រតិកម្ម?

ខ- ចូរគូសដ្យាក្រាមថាមពលប្រតិកម្ម។

2. នៅសីតុណ្ហភាព 25 $^oC$ គេប្រើទឹកដើម្បីរំលាយសមាសធាតុពីរ។ គេវាស់សីតុណ្ហភាពរបស់សូលុយស្យុងនីមួយៗភ្លាម បន្ទាប់ពីសមាសធាតុរលាយអស់។

| សមាសធាតុ | សីតុណ្ហភាពសូលុយស្យុង ($^oC$) |
|---|---|
| អាម៉ូញ៉ូមនីត្រាត | ២១ |
| កាល់ស្យូមក្លរួ | ៤៥ |

ក- ចូរគណនាបម្រែបម្រួលសីតុណ្ហភាពរបស់សូលុយស្យុងនីមួយៗ។

ខ- តើសមាសធាតុណាដែលរលាយដោយបញ្ចេញកម្តៅ ?

គ- តើសមាសធាតុណាដែលរលាយដោយស្រូបកម្តៅ ?

ឃ- ចំពោះសូលុយស្យុងនីមួយៗ ចូរប៉ាន់ស្មានសីតុណ្ហភាពរបស់ សូលុយស្យុងប្រសិនបើ

(i) គេប្រើម៉ាសសមាសធាតុដដែល ប៉ុន្តែប្រើទឹកតែពាក់កណ្តាល។

(ii) គេប្រើម៉ាសសមាសធាតុតែពាក់កណ្តាល តែរក្សាបរិមាណទឹកនៅដដែល។

(iii) គេប្រើម៉ាសសមាសធាតុ និងម៉ាសទឹកតែពាក់កណ្តាល។

3. មេតានគឺជាធាតុផ្សំសំខាន់នៃឧស្ម័នធម្មជាតិ។ ប្រតិកម្មរវាងមេតាន និងអុកស៊ីសែនគឺជាប្រតិកម្មបញ្ចេញកម្តៅ ដែលផ្តល់ ថាមពល 890 kJ ។

$$CH_4\ (g) + 2O_2\ (g) \longrightarrow CO_2(g) + H_2O\ (g)$$

ក- ហេតុអ្វីបានជាប្រតិកម្មនេះជាប្រតិកម្មបញ្ចេញកម្តៅ? ចូរពន្យល់ដោយផ្អែកលើការផ្តាច់ និងការកកើតសម្ព័ន្ធ។

ខ- (i) ចូរគូសដ្យាក្រាមបង្ហាញពីថាមពលប្រតិកម្មនេះ និងថាមពលសកម្មកម្ម។




(ii) ហេតុអ្វីបានជាមេតានមិនឆេះក្នុងខ្យល់ កាលណាគេមិនបំព្រាយផ្កាភ្លើង ឬផ្តល់អណ្តាតភ្លើងឱ្យវា?

គ- តើវានឹងផ្តល់នូវថាមពលប៉ុន្មាននៅពេលគេដុតមេតាន 1 g ?

4. អ៊ីដ្រូសែនពែអុកស៊ីតបំបែកយ៉ាងយឺតបង្កើតបានជាទឹក និងអុកស៊ីសែន ។

$$2H_2O_2\ (aq) \longrightarrow 2\ H_2O\ (l) + O_2\ (g)$$

ក- គេអាចបន្ថែមកាតាលីករនៅក្នុងប្រតិកម្មនេះ ។ តើកាតាលីករមានតួនាទីដូចម្ដេច?

ខ- នេះគឺជាដ្យាក្រាមថាមពលនៃប្រតិកម្មខាងលើ ។




(i) តើពាក្យថា ថាមពលសកម្មកម្មមានន័យដូចម្ដេច?

(ii) តើបម្រែបម្រួលថាមពលមួយណា A, B, C ឬ D ជាថាមពលសកម្មកម្ម ។

(iii) តើប្រតិកម្មនេះជាប្រតិកម្មបញ្ចេញ ឬស្រូបកម្ដៅ?

គ- គេប្រើរូបមន្តគ្រោងក្នុងសមីការខាងក្រោមនេះតាងឱ្យប្រតិកម្មបំបែកអ៊ីដ្រូសែនពែអុកស៊ីត ។

2(H-O-O-H) 2 (H-O-H) + O=O

តារាងខាងក្រោមនេះបង្ហាញពីថាមពលសម្ព័ន្ធ ។

| **សម្ព័ន្ធ** | **ថាមពលដែលត្រូវការ** (kJ) |
|---|---|
| O=O | 498 |
| O-O | 146 |
| H-O | 464 |

(i) គណនាថាមពលដែលត្រូវការដើម្បីបំបែកសម្ព័ន្ធទាំងអស់នៅក្នុងអង្គធាតុប្រតិករ ?

(ii) ចូរគណនាថាមពលដែលបញ្ចេញនៅពេលសម្ព័ន្ធថ្មីកកើត នៅក្នុងផលិតផល ។

(iii) ចូរគណនាបម្រែបម្រួលថាមពលនៅក្នុងប្រតិកម្មនេះ ។

(iv) តើប្រតិកម្មនេះជាប្រតិកម្មស្រូប ឬបញ្ចេញកម្ដៅ ? ចូរពន្យល់នូវចម្លើយរបស់អ្នក និងប្រៀបធៀបចម្លើយនៅចំនុច ខ iii ខាងលើ ។

5. ក្នុងប្រតិកម្មបំបែកមេតាន ត្រូវការស្រូបថាមពល 1664 kJ ។



$\longrightarrow\ C\ (g) + 4\ H\ (g)$

(នៅក្នុងប្រតិកម្មនេះគ្មានសម្ព័ន្ធថ្មីកកើតទេ)

ក- ហេតុអ្វីបានជាប្រតិកម្មនេះជាប្រតិកម្មស្រូបកម្ដៅ ?

ខ- តើមានសម្ព័ន្ធប៉ុន្មានបានដាច់នៅក្នុងប្រតិកម្មនេះ ?

គ- ចូរគណនាថាមពលសម្ព័ន្ធ C-H ។

ឃ- ដូចគ្នានេះដែរប្រតិកម្មបំបែកអេតាន ត្រូវការស្រូបយកថាមពល 2826 kJ ។

(i) ចូររៀបរាប់សម្ព័ន្ធដែលបានដាច់ពេលមានប្រតិកម្ម ?

(ii) ចូរគណនាថាមពលសម្ព័ន្ធ C-C ។

6. អ៊ីដ្រាស៊ីន $N_2H_4$ ឆេះក្នុងអុកស៊ីសែនតាមសមីការដូចខាងក្រោម

$$NH_2\text{-}NH_2\,(g) + O{=}O\,(g) \longrightarrow N{\equiv}N\,(g) + 2\,O{=}O\,(g)$$

ក- ចូររៀបរាប់សម្ព័ន្ធដែលបានដាច់នៅក្នុងប្រតិកម្មនេះ ?

ខ- ចូររៀបរាប់សម្ព័ន្ធដែលកកើតថ្មី ?

គ- ចូរគណនាថាមពលសរុប

(i) ត្រូវការដើម្បីផ្ដាច់សម្ព័ន្ធ

(ii) បញ្ចេញនៅពេលដែលសម្ព័ន្ធថ្មីកកើត

(ថាមពលសម្ព័ន្ធគិតជា kJ, N-H 391; N-N 158; N≡N 945; O-H 464; O=O 498;)

ឃ- ចូរគណនាបម្រែបម្រួលថាមពលប្រតិកម្មនេះ?

ង- តើប្រតិកម្មនេះជាប្រតិកម្មស្រូប ឬបញ្ចេញកម្ដៅ ?

ច- តើអ៊ីដ្រាស៊ីនអាចជាឥន្ធនៈសមស្របទេ ? ហេតុអ្វី ?

7. នៅពេលគេឱ្យឧស្ម័នក្លរឆ្លងកាត់អ៊ីយ៉ូត ប្រតិកម្មខាងក្រោមនេះកើតមានឡើង ។

*ប្រតិកម្ម ១* $I_2(s) + Cl_2(g) \longrightarrow 2\,ICl\,(l)$

ពណ៌ត្នោត

*ប្រតិកម្ម ២* $ICl\,(l) + Cl_2(g) \rightleftharpoons ICl_3\,(s)$

ពណ៌ត្នោត ពណ៌លឿង

ក- តើអ្វីជាបម្រែបម្រួលដំបូងដែលអ្នកអាចមើលឃើញនៅ ពេលដែលក្លរឆ្លងកាត់អ៊ីយ៉ូត ?

ខ- នៅពេលដែលក្លរឆ្លងកាត់កាន់តែច្រើន តើបម្រែបម្រួលអ្វីទៀតដែលអ្នកអាចឃើញ ។

គ- តើប្រតិកម្មមួយណាអាចច្រាសមកវិញ?

ឃ- តើមានបម្រែបម្រួលអ្វីដែលអ្នកអាចឃើញនៅពេលដែលគេបញ្ឈប់ក្លរមិនឱ្យឆ្លងកាត់អ៊ីយ៉ូតទៀត? ចូរពន្យល់ ។

8. អ៊ីដ្រូសែនមានប្រតិកម្មជាមួយប្រូមបង្កើតបានជា អ៊ីដ្រូសែនប្រូមួ ។

$$H_2(g) + Br_2(g) \rightleftharpoons 2HBr\,(g)$$

ក- តើកត្តាមួយណាក្នុងចំណោមកត្តាខាងក្រោមនេះដែល ជួយសម្រួលដល់ការបង្កើតអ៊ីដ្រូសែនប្រូមួ ?

(i) បន្ថែមអ៊ីដ្រូសែន

(ii) យកប្រូមចេញ

(iii) យកផលិតផលចេញភ្លាមនៅពេលវាកើតមាន

ខ- ហេតុអ្វីបានជាការបង្កើនសំពាធគ្មានឥទ្ធិពលទៅលើផលិតផលដែលកកើត? ចូរពន្យល់។

9. គេផលិតអាម៉ូញាក់ពីអ៊ីដ្រូសែន និង អាសូត។ ក្នុងប្រតិកម្មនេះវាផ្តល់នូវថាមពល 92 kJ។

ក- តើប្រតិកម្មទៅជាប្រតិកម្មស្រូប ឬបញ្ចេញកម្តៅ ?

ខ- ចូរពន្យល់ថាហេតុអ្វីបានជាទិន្នផលរបស់អាម៉ូញាក់ ÷

(i) កើនឡើងនៅពេលសម្ពាធកើន។

(ii) ថយចុះនៅពេលសីតុណ្ហភាពកើន។

គ- ហេតុអ្វីបានជាគេអនុវត្តប្រតិកម្មនេះនៅសីតុណ្ហភាព 450 $^0$C មិនមែននៅសីតុណ្ហភាពក្រោមនេះ។

10. លំនាំ Haber បំលែងអាសូត និងអ៊ីដ្រូសែនឱ្យទៅជាអាម៉ូញាក់។

$$N_2(g) + 3H_2(g) \rightleftharpoons 2NH_3\,(g)$$

ក- ខាងក្រោមនេះបង្ហាញពីដ្យាក្រាមកម្រិតថាមពលរបស់ប្រតិកម្មខាងលើ។ តើដ្យាក្រាមនេះប្រាប់អ្នកយ៉ាងដូចម្តេចអំពី ប្រតិកម្មនេះ ?




ខ- ប្រតិកម្មនេះជាប្រតិកម្មទៅមក ហើយវានឹងឈានទៅ ដល់លំនឹង។

(i) តើកាតាលីករមានឥទ្ធិពលអ្វីទៅលើប្រតិកម្មពេលមានលំនឹង

(ii) តើគេប្រើកាតាលីករអ្វីនៅក្នុងលំនាំ Haber ?

គ- សមីការបីខាងក្រោមនេះបង្ហាញពីការផលិតអាស៊ីតនីទ្រិច

ពីអាម៉ូញាក់។

អាម៉ូញាក់ + អុកស៊ីសែន $\rightarrow$ អាសូតម៉ូណូអុកស៊ីត + ចំហាយទឹក

អាសូតម៉ូណូអុកស៊ីត + អុកស៊ីសែន $\rightarrow$ អាសូតឌីអុកស៊ីត

អាសូតឌីអុកស៊ីត + អុកស៊ីសែន + ទឹក $\rightarrow$ អាស៊ីតនីទ្រិច

(i) អាម៉ូញាក់ជារូបធាតុដើមនៅក្នុងលំនាំនេះ តើរូបធាតុដើមពីរទៀតជាអ្វី ?

(ii) បម្រើបម្រាស់មួយរបស់អាស៊ីតនីទ្រិចគឺដើម្បីផលិត អាម៉ូញ៉ូមនីត្រាត។ ចូរសរសេរសមីការតាងប្រតិកម្មនេះ។

(iii) តើគេប្រើអាម៉ូញ៉ូមនីត្រាតដើម្បីអ្វី ?